ក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ៣៤៣៦.អ.ក.រប

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តម និងលោកប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល**

**កម្មវត្ថុ** : ស្តីពីការផ្សព្វផ្សាយសេចក្តីជូនដំណឹងការប្រឡងជ្រើសរើសអាហារូបករណ៍ថ្នាក់បណ្ឌិត ថ្នាក់អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រ ចំនួន២៦០កន្លែង ក្រោមគម្រោងព្រះរាជឧបត្ថម្ភរបស់ ព្រះអង្គម្ចាស់ក្សត្រីយ៍មហាចក្រី **សារិនថន** សម្រាប់ឆ្នាំសិក្សា២០១៨ នៅព្រះរាជាណាចក្រថៃ។

**យោង** : លិខិតលេខ៨១ អយក.សជណ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម** និង **លោកប្រធាន** ថា ក្រោមគម្រោងព្រះរាជឧបត្ថម្ភរបស់ព្រះអង្គម្ចាស់ក្សត្រីយ៍មហាចក្រី **សារិនថន** បានផ្តល់អាហារូបករណ៍ជូនព្រះរាជាណាចក្រកម្ពុជាចំនួន **២៦០**កន្លែង ដល់សិស្ស និស្សិត មន្ត្រីរាជការ សាធារណៈជនទូទៅ និងសិស្ស-គ្រូនៃវិទ្យាល័យកំពង់ឈើទាល សិស្សនៅខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងនិស្សិតកំពុងសិក្សានៅប្រទេសថៃ ដើម្បីទៅបន្តការសិក្សាថ្នាក់បណ្ឌិត ថ្នាក់អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រតាមគ្រឹះស្ថានអប់រំប្រមាណ៣៨ នៅព្រះរាជាណាចក្រថៃ។

សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌជ្រើសរើសផ្សេងៗមានដូចខាងក្រោម ៖

I. **លក្ខណសម្បត្តិដើម្បីដាក់ពាក្យសុំអាហារូបករណ៍**

**បេក្ខជនទាំងពីរភេទត្រូវ៖**

**ក. ថ្នាក់បណ្ឌិត**

- មានសញ្ជាតិខ្មែរ
- មានអាយុយ៉ាងច្រើន៤០ឆ្នាំ (គិតដល់ថ្ងៃដាក់ពាក្យ)
- ត្រូវចេះភាសាអង់គ្លេសច្បាស់លាស់
- មានសុខភាពល្អទាំងកាយសម្បទា និងសតិបញ្ញា
- មានសញ្ញាបត្រថ្នាក់អនុបណ្ឌិត (ភ្ជាប់ព្រឹត្តិបត្រពិន្ទុ)
- មានបទពិសោធន៍ការងាររដ្ឋ អង្គការផ្សេងៗ ឬក្រុមហ៊ុនឯកជនយ៉ាងតិច០២ឆ្នាំ
- សរសេរ CV ជាភាសាអង់គ្លេស ឬថៃ

**ខ. ថ្នាក់អនុបណ្ឌិត**

- មានសញ្ជាតិខ្មែរ
- មានអាយុយ៉ាងច្រើន៤០ឆ្នាំ (គិតដល់ថ្ងៃដាក់ពាក្យ)
- ត្រូវចេះភាសាអង់គ្លេសច្បាស់លាស់
- មានសុខភាពល្អទាំងកាយសម្បទា និងសតិបញ្ញា

- មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ (ភ្ជាប់ព្រឹត្តិបត្រពិន្ទុ)
- មានបទពិសោធន៍ការងាររដ្ឋ អង្គការផ្សេងៗ ឬក្រុមហ៊ុនឯកជនយ៉ាងតិច០២ឆ្នាំ
- សរសេរ CV ជាភាសាអង់គ្លេស ឬថៃ

**គ. ថ្នាក់បរិញ្ញាបត្រ**

- មានសញ្ជាតិខ្មែរ
- មានអាយុយ៉ាងច្រើន២៥ឆ្នាំ (គិតដល់ថ្ងៃដាក់ពាក្យ)
- មានសុខភាពល្អទាំងកាយសម្បទា និងសតិបញ្ញា
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ

## II. សំណុំឯកសារត្រូវបំពេញ និងភ្ជាប់មកជាមួយ

- ពាក្យសុំអាហារូបករណ៍ ០១ច្បាប់ (មានគំរូ)
- ជីវប្រវត្តិសង្ខេប ០១ច្បាប់ (មានគំរូ)
- កិច្ចសន្យា ០១ច្បាប់ (មានគំរូ)
- បង្កាន់ដៃទទួលពាក្យ ០១ច្បាប់ (មានគំរូ)
- រូបថត ៤x៦ (ទើបថតថ្មី ផ្ទៃពណ៌ស) ០៤សន្លឹក (ទើបថតថ្មី)
- សញ្ញាបត្រថ្នាក់អនុបណ្ឌិត ថតចម្លង០១ច្បាប់សម្រាប់ថ្នាក់បណ្ឌិត
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ថតចម្លង០១ច្បាប់សម្រាប់ថ្នាក់អនុបណ្ឌិត
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ថតចម្លង០១ច្បាប់សម្រាប់ថ្នាក់បរិញ្ញាបត្រ (សូមភ្ជាប់ច្បាប់ដើមដើម្បីមកជាមួយដើម្បីផ្ទៀងផ្ទាត់)
- លិខិតបញ្ជាក់ការសិក្សាពីគ្រឹះស្ថានសិក្សាចំពោះនិស្សិតកំពុងដែលកំពុងសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សា
- លិខិតបញ្ជាក់ពីអង្គភាពចំពោះបេក្ខជនជាមន្ត្រីរាជការ
- វិញ្ញាបនបត្រពិនិត្យកាយសម្បទា (០២ច្បាប់) ក្រោយពេលបេក្ខជនត្រូវបានជ្រើសរើស

## III. វិញ្ញាសាប្រឡង

**ក. ថ្នាក់បណ្ឌិត**

- ភាសាអង់គ្លេស រយៈពេល (១ម៉ោង៣០នាទី)

**ខ. ថ្នាក់អនុបណ្ឌិត**

- ភាសាអង់គ្លេស រយៈពេល (១ម៉ោង៣០នាទី)

**គ. ថ្នាក់បរិញ្ញាបត្រ**

➢ សម្រាប់ជំនាញវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ (Social Sciences and Humanities):

- ភាសាអង់គ្លេស រយៈពេល (១ម៉ោង៣០នាទី)

➢ សម្រាប់ជំនាញវិទ្យាសាស្ត្រធម្មជាតិ (Natural Sciences):

- គណិតវិទ្យា រយៈពេល (១ម៉ោង៣០នាទី)
- ភាសាអង់គ្លេស រយៈពេល (១ម៉ោង៣០នាទី)

IV. **កាលបរិច្ឆេទប្រឡង និងទីកន្លែង**

➢ សម្រាប់បេក្ខជនទូទៅ

- ការប្រឡងនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៧
- មណ្ឌលប្រឡងនឹងជម្រាបជូននៅពេលក្រោយ

➢ សម្រាប់សិស្ស-គ្រូវិទ្យាល័យកំពង់ឈើទាល សិស្សនៅខេត្តមណ្ឌលគិរី និងខេត្តរតនគិរី

- សម្រាប់សិស្ស-គ្រូវិទ្យាល័យកំពង់ឈើទាលប្រឡងនៅថ្ងៃទី១១-១២ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅវិទ្យាល័យកំពង់ឈើទាល
- សម្រាប់សិស្សនៅខេត្តមណ្ឌលគិរី ប្រឡងនៅថ្ងៃទី១៣-១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅខេត្តមណ្ឌលគិរី
- សម្រាប់សិស្សនៅខេត្តរតនគិរី ប្រឡងនៅថ្ងៃទី១៥-១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅខេត្តរតនគិរី
- មណ្ឌលប្រឡងទាំងបីខាងលើនឹងរៀបចំឡើងដោយភាគីថៃ ដែលមានកិច្ចសហការពីក្រសួងអប់រំ យុវជន និងកីឡា

V. **ទីកន្លែងទទួលពាក្យ**

ការទទួលពាក្យប្រឡងនឹងចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ម៉ោង១៦:០០ល្ងាចនៅការិយាល័យអាហារូបករណ៍ និងកម្មវិធីសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ដែលមានអាសយដ្ឋាន អគារលេខ២៣ ផ្លូវ៣៦០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន (ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាចម្ងាយ៥០ម៉ែត្រ)។ ផ្អែកលើលទ្ធផលប្រឡងជំហានទី១ ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ភាគីថៃនឹងធ្វើការជ្រើសរើសបេក្ខជនប្រឡងជំហានទី២ នឹងធ្វើការសម្ភាសន៍បន្តបន្ទាប់តាមចំនួនជាក់ស្តែងនៅថ្ងៃទី១៦-១៨ ខែធ្នូ ឆ្នាំ២០១៧។

ចំពោះព័ត៌មានលម្អិតទាក់ទងនឹងអាហារូបករណ៍នេះ អាចសាកសួរដោយផ្ទាល់នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សាតាមអាសយដ្ឋានខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** និង**លោកប្រធាន** ជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម** និង**លោកប្រធាន** ទទួលនូវការគោរពអានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ **សំអឿន**


សូមទំនាក់ទំនង៖

- លោក ងួន គីមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧